អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ពុទ្ធភាសិតមួយបទពោលថាបុគ្គលមិនគប្បីធ្វើបាបក្នុងទីស្ងាត់ឡើយ ព្រោះទីស្ងាត់ពុំមានក្នុងលោកឡើយ ។

website: www.hoksavann.org
ថ្ងៃទី១០ កុម្ភៈ ២០០៨



ពាក្យថា ធ្វើបានក្នុងទីស្ងាត់ក្នុងទីនេះ សំដៅយកការធ្វើបាបមិនឲ្យអ្នកណាដឹង គឺធ្វើអំពើណាមួយ ដែលទាក់ទងនឹងការប៉ះសិទ្ធិអ្នកដទៃ ក៏ខំបិទបាំងមិនឲ្យគេឃើញ ឬមិនឲ្យគេដឹងឮរឿងនោះ គឺលួចធ្វើ ឬប្រើល្បិចកិច្ចកលបង្វែងដាន មានពាក្យមួយហៅថាលាក់ការ ។ តាមផ្លូវអាណាចក្រ ការប្រព្រឹត្តធ្វើអំពើអាក្រក់គ្រប់យ៉ាងរបស់មនុស្ស បើគ្មានគេដឹងឮ គ្មានគេឃើញជាសាក្សី គ្មានវត្ថុជាភស្តុតាង ឬសាមីខ្លួនពុំទទួលសារភាពទេ តុលាការមិនអាចកាត់ឲ្យមានទោសឡើយ ព្រោះមិនមានភស្តុតាង ។ ចំណែកច្បាប់ផ្លូវធម៌ ឬច្បាប់ធម្មជាតិវិញ អ្នកប្រព្រឹត្តអំពើបាបរមែងសៅហ្មងចិត្តដោយខ្លួនឯងរួចទៅហើយ មិនសំខាន់នៅលើអ្នកដទៃដឹងឮឡើយ ។ បើអ្នកដទៃពុំដឹងឮ ក៏អ្នកប្រព្រឹត្តធ្វើអំពើបាប រមែងក្តៅក្រហាយចិត្ត និងទទួលផលបាបក្នុងពេលណាមួយពុំខានឡើយ ។ បាបនិងបុណ្យពុំមែនស្ថិតនៅលើការធ្វើឬមិនធ្វើឡើយ តែត្រូវស្ថិតនៅលើអំពើដែលគេធ្វើ បើគេធ្វើអំពើបែបណាតែងបានផលបែបនោះ ធ្វើបាបបានបាបធ្វើបុណ្យបានបុណ្យ ។ នេះជាហេតុផលរបស់ច្បាប់ធម្មជាតិ ដែលមានចលនាកម្មនិងផលរបស់កម្ម ប្រព្រឹត្តទៅដោយខ្លួនឯងជាស្វ័យប្រវត្តិ ។ អំពើគ្រប់យ៉ាងតែងមានផល ពុំមានអំពើណាមួយកើតឡើងដោយគ្មានផលនោះឡើយ ។

ព្រះពុទ្ធប្រៀបប្រដៅមនុស្សសត្វ កុំឲ្យធ្វើអំពើបាប ទោះបីក្នុងទីកំបាំងក៏ដោយ ព្រោះអំពើបាប តែងតែផ្តល់ផលជាទុក្ខ ។ ព្រះពុទ្ធមានព្រះនាមថាអរហំ ព្រោះព្រះអង្គ

ឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ជាអ្នកមិនមានទីកំបាំង គឺព្រះអង្គមិនធ្វើបាបក្នុងទីកំបាំង ព្រោះឫសគល់ដែលនាំឲ្យសាងបាបកម្ម ព្រះអង្គបានលះបង់អស់ហើយ ។ បើសង្គមមនុស្ស ជាពិសេសសង្គមខ្មែរនាំសិក្សានិងអនុវត្តតាមពាក្យប្រៀនប្រដៅនេះឲ្យបានម៉ត់ចត់ និងបានទទួលសេចក្ដីសុខស្ងប់ពុំខានឡើយ ដោយសារមនុស្សមិនសាងអំពើបាបដោយការបៀតបៀនគ្នា ។ អ្នកដែលធ្វើអំពើបាបដោយមិនដឹងថាបាបក្ដី អ្នកដឹងហើយនៅតែប្រព្រឹត្តធ្វើក្ដី តែងតែទទួលផលនៃបាប នឹងធ្វើឲ្យសង្គមមនុស្សទទួលគ្រោះថ្នាក់ ។ ព្រះពុទ្ធបានពន្យល់មនុស្សឲ្យឃើញទោសនៃអំពើបាប រហូតខ្លាចមិនហ៊ានធ្វើ ។ ការពិចារណាមានកំរិតខ្ពស់ ដើម្បីបន្ថយបន្តិចម្ដងៗនូវការមិនធ្វើអំពើបាប គឺពិចារណានូវភាពមិនទៀងនៃអ្វីទាំងអស់ រួមទាំងខន្ធ៥របស់ខ្លួនផង ។ របស់អ្វីមួយក្នុងលោកពុំមែននៅជាដដែលទេ វត្ថុមួយកើតមានក្នុងថ្ងៃនេះ ពុំមែនដូចរបស់ដែលកើតមានពីម្សិលមិញទេ ហើយក៏ពុំដូចជារបស់អ្វីមួយ ដែលនឹងកើតឡើងក្នុងថ្ងៃស្អែកដែរ នេះជាធម្មតានៃរបស់ដែលកើតឡើងក្នុងលោក ដែលជាអនិច្ចតាធម៌ ។

ព្រះពុទ្ធត្រាស់ដឹងធម៌ ឃើញអំពើបាបនិងបុណ្យ មានហេតុផលក្នុងខ្លួនរបស់វា ដែលមានលក្ខណៈផ្ទុយពីសាសនាដទៃដែលពោលថា បុណ្យបាបគុណទោស និងរបស់អ្វីៗទាំងអស់ កើតឡើងពីព្រះអទិទេព ពុំមែនកើតឡើងអំពីអំពើផ្ទាល់ខ្លួនទេ ។ ការពោលនេះ ពុំអាចមានអ្វីបញ្ជាក់បានថាជាការពិតតាមលក្ខណៈវិទ្យាសាស្ត្រទេ ។ ព្រះពុទ្ធសាសនាសំដែងថា អំពើប្រកបដោយចេតនាល្អអាក្រក់មនុស្សសត្វនេះឯង ជាធម្មជាតិបែងចែកវាសនារបស់មនុស្សសត្វពុំមែនព្រះអាទិទេពទេ ។ បើល្អអាក្រក់ស្ថិតនៅលើព្រះអាទិទេពពិតមែន យើងត្រូវតែឲ្យតម្លៃឬសរសើរគុណព្រះអាទិទេពចំពោះហេតុការណ៍ល្អកើតឡើង ប៉ុន្តែយើងត្រូវតែផ្ដន្ទាទោសព្រះអាទិទេព ចំពោះហេតុការណ៍អាក្រក់កើតឡើងនេះទើបយុត្តិធម៌ ព្រោះអ្វីព្រោះថាបើមិនដាក់ទោសដល់ព្រះអាទិទេព ដែលធ្វើឲ្យមនុស្សលោកមានទុក្ខទេ នោះជាអំពើអយុត្តិធម៌ខ្លាំងណាស់មកលើមនុស្សមានទុក្ខទេ នោះជាអំពើអយុត្តិធម៌ខ្លាំងណាស់មកលើមនុស្សលោកដែលជាអ្នកទន់ខ្សោយ ហើយតើអ្នកណាប្រគល់អំណាចផ្ដាច់ការនេះដល់ព្រះអង្គ ។ ពុទ្ធសាសនាពោលស្របតាមច្បាប់ផ្លូវអាណាចក្រសព្វថ្ងៃ គឺគេសរសើរគុណដល់មនុស្សណាធ្វើត្រូវ ហើយគេផ្ដន្ទាទោសដល់មនុស្សដែលធ្វើខុសរំលោភសិទ្ធិមនុស្ស ។ ដូចបានពោលមកហើយនូវពុទ្ធភាសិតថា បុគ្គលមិនគប្បីធ្វើបាបក្នុងទីស្ងាត់ឡើយ ព្រោះទីស្ងាត់មិនមានក្នុងលោកឡើយ គឺព្រះពុទ្ធសំដែងអំពីចេតនាអាក្រក់ផ្លូវចិត្ត បើចិត្តមានចេតនាអាក្រក់ហើយ ត្រូវសៅហ្មងដោយខ្លួនឯងហើយអំពើបាបកម្មគ្រប់យ៉ាងក៏កើតមានឡើងដោយសារចិត្តសៅហ្មង ហើយផលនៃអំពើបាបជាទុក្ខក៏កើតឡើង ខ្លួនឯងដឹងខ្លួនឯង មិនសំខាន់នៅលើអ្នកដទៃដឹង ឬពុំដឹងឡើយ ។៚